# ព័ត៌មានសម្រាប់ជួយឲ្យ ត្រៀមខ្លួន នៅពេលមានអាសន្ន

FEMA សម្រាប់ក្មេង
[http://www.fema.gov/kids/](http://www.fema.gov/kids/)

វិទ្យាស្ថានសិក្សាវិធីចាត់ចែងភាពអាសន្ន
(មុខវិជ្ជាសិក្សាដោយឯករាជ្យ)
[http://www.fema.gov](http://www.fema.gov)

ក្រសួងចាត់ចែងភាពអាសន្ននៃរដ្ឋផិនស៊ីលវេញ៉ា
[http://www.pema.state.pa.us](http://www.pema.state.pa.us)

រួចរាល់ ឬ នៅ?/Ready or Not?
[www.readyregion.org](http://www.readyregion.org)

សង្គ្រោះបន្ទាន់ផ្នែកសុខភាពសាធារណៈ:
[http://www.phila.gov/health/Disease Control/Bio_EmergencyFacts.html](http://www.phila.gov/health/DiseaseControl/Bio_EmergencyFacts.html)

កងកម្លាំងជួយពលរដ្ឋ/Citizens Corps
[www.citizencorps.gov](http://www.citizencorps.gov)

កាកបាទក្រហមអាមេរិកាំង/American Red Cross
[www.redcross.org](http://www.redcross.org)

*Translation and Interpretation Center*
8/2012

### ព័ត៌មានសម្រាប់ទាក់ទង

២១៥-៤០០-៤៧១០
២១៥-៤០០-៤៧១១ (ទូរសារ)

[Safetynet@philasd.org](mailto:Safetynet@philasd.org)

នាយកត្រួតពិនិត្យ Myron Patterson
នាយកផ្នែកសន្តិសុខសាលា

Brendan Lee
នាយកប្រតិបត្តិ
សន្តិសុខសាលា

Tricia London
អ្នកទាក់ទងក្នុងការចាត់ចែងពេលមានអាសន្ន

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មាន
បន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ ៖
[www.philasd.org/language/khmer](http://www.philasd.org/language/khmer)

## ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉

ការិយាល័យផ្នែកសន្តិសុខសាលា
ការត្រៀមខ្លួនជាស្រេច និង ការចាត់ចែងពេលមានអាសន្ន

**២១៥-៤០០-SAFE**




# ការចង់ឲ្យមានសន្តិសុខ

ចំណុចសំខាន់ៗសម្រាប់មាតា
បិតា ក្នុងការត្រៀមខ្លួនពេល
មានអាសន្ន និង សន្តិសុខ
សាលា

*Safe Expectations for Parents*
*Khmer*

# ការចង់ឲ្យមានសន្តិសុខ

## មុនពេល

### <u>ទំនាក់ទំនងរបស់មាតាបិតា</u>

កន្លែងដែលមានសន្តិសុខជាងគេសម្រាប់កូនលោកអ្នក នៅពេលមានឧប្បត្តិហេតុធ្ងន់ធ្ងរគឺ នៅសាលារបស់ពួកគេ។ សូមផ្តល់ព័ត៌មានថ្មីៗរបស់លោកអ្នក អំពី៖

- ✓ អ្នកដែលអាចទាក់ទងនៅពេលមានអាសន្ន
- ✓ លេខទូរស័ព្ទ ជិត និង ឆ្ងាយ សម្រាប់ទាក់ទងនៅពេលមានអាសន្ន

### <u>ផែនការសន្តិសុខ</u>

សាលានីមួយៗមានផែនការសន្តិសុខប្រចាំសាលាជាស្រេច ដើម្បីធ្វើយ៉ាងណាឲ្យសិស្ស**ទាំងអស់** មានសន្តិសុខ។ សូមពិនិត្យមើលផែនការនៅសាលារបស់លោកអ្នក៖

- កន្លែងជួបជុំគ្នាពេលមានអាសន្ន
- ការផ្លាស់ប្តូរកន្លែងជំលៀស
- វិធីឆ្លើយតប ជាទូទៅ ចំពោះភាពអាសន្ន

### <u>ការចាត់ចែងភ្ញៀវដែលមកសាលា</u>

គេតម្រូវឲ្យភ្ញៀវ**ទាំងអស់** ចុះហត្ថលេខា នៅពេលមកដល់សាលា នៅតុទទួលភ្ញៀវ ហើយយកផ្លាកសម្រាប់ភ្ញៀវពាក់។ សូមត្រៀមទុកជាស្រេចនូវ៖

- អត្តសញ្ញាណប័ណ្ណដែលរដ្ឋចេញឲ្យ
- ឈ្មោះសិស្ស និង
- គោលបំណងនៃការមកសាលា

**សូមកុំភ្លេចចុះហត្ថលេខាម្តងទៀត**

**មុនពេលលោកអ្នកចាកចេញពីសាលា**

## នៅពេល

**ដើម្បីសន្តិសុខរបស់សិស្សទាំងអស់**

**<u>នៅពេល</u>មានឧប្បត្តិហេតុទូទាំងសាលា មាតាបិតា៖**

- **សូមកុំ** ទៅសាលាភ្លាម
- សូមសហការជាមួយអភិបាលសាលា និងបុគ្គលិក ផ្នែកភាពអាសន្ន

### <u>វិធីឆ្លើយតបជាសាកល ទៅនឹងភាពអាសន្ន</u>

**អោន បាំង និង ទប់៖** សិស្សត្រូវទៅនៅត្រង់ជញ្ជាំងខាងក្នុង ក្រាបដល់ ដី/កម្រាល បិទភ្នែកដោយយកដៃខ្ទប់មុខ ហើយធ្វើដូច្នេះរហូតដល់ពេលគេប្រាប់ថាត្រូវធ្វើដូចម្តេចទៀត។

**ការជំលៀស៖** សិស្សចេញតាមទ្វារដែល នៅជិតជាងគេ និងមានសុវត្ថិភាពជាងគេ ដូចបានបិទប្រកាស។ ធ្វើដូច្នេះនៅពេលដែលស្ថានភាពនៅក្រៅសាលាមានសុវត្ថិភាពជាងស្ថានភាពនៅក្នុងសាលា។

**ជំលៀសចូលសាលាវិញ៖** សិស្សត្រឡប់ចូលអាគារសាលាវិញជាបន្ទាន់។ ធ្វើដូច្នេះនៅពេលដែលស្ថានភាពនៅក្នុងសាលាមានសុវត្ថិភាពជាងស្ថានភាពនៅក្រៅសាលា។

**ចាក់សោទ្វារសាលាមិនឲ្យចេញចូល** - ត្រូវចាក់សោទ្វារចូលសាលាទាំងអស់។ សិស្សត្រូវចាកចេញពីរបៀងសាលាជាបន្ទាន់ ហើយចូលក្នុងបន្ទប់រៀនដែលនៅ ជិតជាងគេ។ គេមិនអនុញ្ញាតឲ្យអ្នកណាម្នាក់ចេញចូលសាលាទេ។

**ជម្រកបន្ទាន់៖** សិស្សត្រូវចាកចេញពីរបៀងសាលាជាបន្ទាន់ ហើយចូលក្នុងបន្ទប់រៀនដែលជិតជាងគេ ឬកន្លែងដែលបានកំណត់ជាមុន។

## ក្រោយពេល

### <u>ការជួបជុំ មាតាបិតា/អាណាព្យាបាល/ក្មេង ឡើងវិញ</u>

ក្នុងគ្រាដែលឧប្បត្តិហេតុនៅសាលាតម្រូវឲ្យសិស្សចេញនៅពេលមានអាសន្ន សាលានឹងខំប្រឹងប្រែង គ្រប់បែបយ៉ាង ដើម្បីទាក់ទងទៅមាតាបិតា និង/ឬ អាណាព្យាបាល។

នៅពេលណាមានការអនុញ្ញាតពី ក្រសួងអប់រំ ឬភ្នាក់ងារសន្តិសុខសាធារណៈ បុគ្គលិកសាលានឹងចាប់ផ្តើមឲ្យសិស្សចេញ <u>**ដោយមានសណ្តាប់ធ្នាប់**</u> ទៅជួបមាតាបិតា និង/ឬ អាណាព្យាបាល។

ដើម្បីឲ្យសាលាអាចបញ្ចេញសិស្សទៅឲ្យមាតាបិតា ឬអ្នកដែលទទួលខុសត្រូវនៅពេលមានអាសន្ន ពួកគាត់ត្រូវតែ៖

- មានឈ្មោះនៅក្នុងប័ណ្ណទាក់ទងពេលមានអាសន្ន (EH-4/ ប័ណ្ណពណ៌ខៀវ) **និង**
- បង្ហាញអត្តសញ្ញាណប័ណ្ណដែលមានរូបថតទៅបុគ្គលិកសាលា